# ច្បាប់ប្រាក់ជំនួយច្រើនបំផុតសំរាប់គ្រួសារ (Maximum Family Grant ឬ MFG) សំរាប់អ្នកទទួលប្រាក់ជំនួយ

**ច្បាប់ MFG:**

ចំនួនប្រាក់ជំនួយច្រើនបំផុត (MAP) របស់លោកអ្នក**<u>នឹងមិន</u>**កើនឡើង ដោយមានបញ្ចូលក្មេងដែលកើតនៅក្នុងគ្រួសាររបស់លោកអ្នក បើសិនជាសមាជិកណាម្នាក់នៅក្នុងគ្រួសាររបស់លោកអ្នកបានទទួលប្រាក់ជំនួយសំរាប់ពេល១០ខែជាបន្តបន្ទាប់នៅមុនពេលកំណើតរបស់ក្មេង ។

**ច្បាប់នេះអនុវត្តចំពោះសមាជិកគ្រប់រូបនៅក្នុងគ្រួសាររបស់លោកអ្នក ដោយគិតបញ្ចូលទាំងក្មេងណាដែលក្លាយទៅជាឪពុកម្តាយ ។**

## ប្រាក់ជំនួយនឹងមិនកើនឡើងឡើយ នៅពេលណា :

- លោកអ្នកឬមនុស្សពេញវ័យណានៅក្នុងសំណុំរឿងបានទទួលប្រាក់ជំនួយសំរាប់ពេល១០ខែជាបន្តបន្ទាប់នៅមុនពេលដែលទារកបានកើតមក ។
- កូនរបស់លោកអ្នកបានទទួលប្រាក់ចំនួន១០ខែជាបន្តបន្ទាប់នៅមុនពេលដែលគាត់មានកូន ។
- កូនណាម្នាក់របស់លោកអ្នកបានទទួលប្រាក់ជំនួយសំរាប់ពេល១០ខែជាបន្តបន្ទាប់នៅមុនពេលទារកបានកើតមក ទោះបីជាលោកអ្នកមិនទទួលប្រាក់ជំនួយសំរាប់ខ្លួនរបស់លោកអ្នកក៏ដោយ ។

**ទារកនេះនឹងនៅតែមានសិទ្ធិទទួល :**

- ជំនួយពីកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វ័រនីញ៉ា (CalWORKs) ដទៃទៀត ដូចជាកិច្ចថែរក្សាក្មេងនៅពេលដែលឪពុកម្តាយទៅធ្វើការ ។
- ជំនួយផ្នែកពេទ្យនៃរដ្ឋកាលីហ្វ័រនីញ៉ា (Medi-Cal) ។
- បណ្ណ័ទិញម្ហូប ។

**ប្រាក់បង់សំរាប់កិច្ចថែរក្សាក្មេងទើបនឹងកើតនឹងត្រូវបានបង់ទៅឱ្យគ្រួសាររបស់លោកអ្នក ហើយដែលមិនត្រូវបានគេយកគិតជាប្រាក់ចំណូលឡើយ ។**

## ច្បាប់ MFG នឹង<u>មិន</u>បានអនុវត្ត :

- បើសិនជាគ្រួសាររបស់លោកអ្នកលែងទទួលប្រាក់ជំនួយសំរាប់ពេលយ៉ាងតិចណាស់ពីរខែជាបន្តបន្ទាប់នៅក្នុងកំឡុងពេល១០ខែ នៅមុនពេលកំណើតកូន ។
- នៅគ្រាដែលក្រុមគ្រួសារទាំងមូលលែងទទួលប្រាក់ជំនួយសំរាប់ពេល២៤ខែជាបន្តបន្ទាប់ ឬក៏ទារកបានទៅរស់នៅជាមួយអ្នកណាដទៃទៀត ។
- បើសិនជាគ្មានមនុស្សពេញវ័យនៅក្នុងគ្រួសាររបស់លោកអ្នកបានទទួលសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរអំពីច្បាប់ MFG យ៉ាងហោចណាស់ចំនួន១០ខែ នៅមុនពេលកំណើតរបស់ក្មេង ។
- នៅពេលដែលឪពុកម្តាយដែលមានទារកនៅក្នុងច្បាប់ MFG នៅពេលដែលគាត់មានអាយុមិនទាន់ពេញវ័យ ក្លាយទៅជាមេគ្រួសារនៃក្រុមគ្រួសារទទួលជំនួយរបស់គាត់ដោយខ្លួនឯង ។ ជាឧទាហរណ៍ : សឿនទទួលជំនួយសំរាប់ខ្លួនឯងនិងសំរាប់កូនស្រីអាយុ១៧ឆ្នាំ ឈ្មោះកូឡាប ។ បើសិនជាកូឡាបមានទារកនៅក្នុងពេលទទួលជំនួយ ប្រាក់ជំនួយនៃគ្រួសារនឹងមិនកើនឡើងឡើយបើសិនជាច្បាប់ MFG យកមកអនុវត្ត ។ នៅពេលដែលកូឡាបមានអាយុ១៨ឆ្នាំឬក៏ប្តូរទីលំនៅចេញ នាងអាចដាក់ពាក្យសុំជំនួយសំរាប់ខ្លួននាងនិងទារករបស់នាង ។
- ចំពោះទារកដែលបានកើតជាមួយអ្នកណាម្នាក់ដែលទទួលជំនួយសំរាប់កូនប៉ុន្តែមិនទទួលសំរាប់ខ្លួនគាត់ បើសិនជាមនុស្សនោះមិនមែនជាឪពុកម្តាយនៃក្មេងដែលទទួលជំនួយ ។ ឧទាហរណ៍ : បើសិនជាម្តាយមីងទទួលជំនួយ CalWORKs សំរាប់តែក្មួយរបស់គាត់ ហើយបន្ទាប់មកម្តាយមីងមានកូនរបស់គាត់ផ្ទាល់ ច្បាប់ MFG នឹងមិនបានអនុវត្តចំពោះទារករបស់ម្តាយមីងឡើយ ។
- បើសិនជាទារកត្រូវបានចាប់កំណើតដោយសារតែការរំលោភឬការខូចកាចនៅក្នុងគ្រួសារ ។ លោកអ្នកត្រូវតែរាយការណ៍អំពីការរំលោភឬការខូចកាចក្នុងគ្រួសារនេះ ដោយមិនឱ្យយូរជាងបីខែបន្ទាប់ពីកំណើតរបស់ក្មេងទៅឱ្យ : អ្នកមានវិជ្ជាជីវៈផ្នែកពេទ្យឬជម្ងឺសតិបញ្ញា ឬភ្នាក់ងារសង្គមកិច្ច ឬភ្នាក់ងារមានសមត្ថកិច្ច ។

  នៅក្នុងករណីមានការខូចកាចនៅក្នុងគ្រួសារ លោកអ្នកមិនត្រូវការរាយការណ៍ទេ បើសិនជាភាពជាឪពុកត្រូវបានបង្កើតឡើងរួចហើយ ។
- បើសិនជាទារកត្រូវបានចាប់កំណើតដោយសារតែការមិនមានប្រសិទ្ធិភាពនៃកិច្ចការពារកំណើតកូនទាំងនេះ :
  - IUD (ប្រដាប់ដាក់នៅក្នុងស្បូន), វិធីបញ្ចុះថ្នាំក្នុងដើមដៃស្ត្រីការពារកំណើតកូន (Norplant), វិធីចាក់ថ្នាំការពារកំណើតកូន (Depo-Provera) ឬ
  - វិធីក្រៀវឪពុកឬម្តាយ ។

  លោកអ្នកត្រូវតែផ្តល់ភស្តុតាងផ្នែកពេទ្យនៃការគ្មានប្រសិទ្ធិភាពនៃរបៀបការពារកំណើតកូនដូចបានចុះខាងលើ ។

---

- **ខ្ញុំបានអានសេចក្តីប្រកាសនេះ ឬត្រូវបានគេអានឱ្យស្តាប់ និងខ្ញុំយល់ថា ខ្ញុំនឹងមិនទទួលប្រាក់ជំនួយជាបន្ថែមទៀតទេសំរាប់ទារកដែលបានកើតចំនួន១០ខែបន្ទាប់ពីគ្រួសាររបស់ខ្ញុំទទួលជំនួយ ។ នេះគិតបញ្ចូលទាំងទារកដែលជាកូនបង្កើតរបស់ខ្ញុំ ឬជាចៅបង្កើតរបស់ខ្ញុំ ។**

- **ខ្ញុំយល់ថា ខ្ញុំត្រូវពន្យល់អំពីច្បាប់នេះប្រាប់សមាជិកគ្រប់អាយុទាំងឡាយនៅក្នុងគ្រួសារ ដែលអាចមានផ្ទៃពោះ ឬក្លាយទៅជាឪពុកម្តាយ និងខ្ញុំយល់ថាច្បាប់អនុវត្ត ទោះបីជាខ្ញុំពន្យល់ឬមិនពន្យល់ប្រាប់កូនមិនទាន់ពេញវ័យ ប្តីប្រពន្ធរបស់ខ្ញុំ ឬឪពុកឬម្តាយម្ខាងទៀតរបស់ក្មេង ។**

| ហត្ថលេខានៃអ្នកថែរក្សាជាសាច់ញាតិ | កាលបរិច្ឆេទ |
| --- | --- |
| | |